ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីអំពី

## ការបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រី

## សំរេច

## ជំពូក ១

## អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

មាត្រា ១ .- ត្រូវបានបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ហៅកាត់ អបជអ ដែលមានស្វ័យភាពរដ្ឋបាល ។

មាត្រា ២ ._ អបជអ ជាស្ថាប័នជាតិមួយ ដែលប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាព សមត្ថភាព និងភាពស្អាតស្អំ ហើយដែលធ្វើសេវាសាធារណៈ ទាក់ទងនឹងបញ្ហាអេដស៍ ដោយមិនយកចំណេញ ឬឥតគិតថ្លៃ ។

## ជំពូក ២

## គោលដៅ និង សកម្មភាព

មាត្រា ៣ ._ អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ មានគោលដៅប្រយុទ្ធនឹងជម្ងឺអេដស៍ សំដៅបង្ការទប់ស្កាត់ និងបន្ថយល្បឿន ការរីកដាលនៃជម្ងឺនេះ ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ មានតួនាទីកំណត់ន័យ និងយុទ្ធសាស្ត្រ លើកផែនការសម្របសម្រួល ជំរុញការអនុវត្តន៍ ការតាមដាន និងវាយតម្លៃរាល់សកម្មភាពទាំងឡាយ ដើម្បីសំរេចបាននូវគោលដៅខាងលើ ។

មាត្រា ៤ ._ អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ មានភារកិច្ចដូចតទៅ ៖

_សំរបសំរួល សហការអនុវត្តផែនការ យុទ្ធសាស្ត្រ កម្មវិធី ជាមួយនឹងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធនានា អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នឯកជន ។

អបជអ ផ្លាស់ប្តូរបច្ចេកទេស និងបទពិសោធន៍ ជាមួយប្រទេសទាំងឡាយណាដែលមានបញ្ហាអេដស៍ ។

_ស្រាវជ្រាវអេពីដេមីសាស្ត្រ និងស្រាវជ្រាវផលប៉ះពាល់ ផ្នែកសេដ្ឋកិច្ច_សង្គមកិច្ចនៃជំងឺអេដស៍ ។

_រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងជំងឺអេដស៍ ។

_បណ្តុះបណ្តាល និងបង្កើនសមត្ថភាពគ្រប់គ្រងបុគ្គលិក សំរាប់ប្រយុទ្ធនឹងជំងឺអេដស៍ ។

_អប់រំសុខភាពតាមគ្រប់វិធីដែលមាន ធ្វើអោយយល់ដឹងអំពីគ្រោះថ្នាក់ ដែលបណ្តាលមកពីជំងឺអេដស៍ និងផ្សព្វផ្សាយវិធីបង្ការការចំលងជំងឺអេដស៍ ។

_ចាត់វិធានការលើក្រុមមនុស្ស ដែលមានមុខរបរប្រឈមមុខនឹងគ្រោះថ្នាក់ នៃការឆ្លងរោគអេដស៍ ។

_ណែនាំអំពីការគ្រប់គ្រង ក្នុងការថែទាំអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ។

_បង្កើត និងសម្របអត្ថបទច្បាប់ ស្តីអំពីការត្រួតពិនិត្យ និង ការអនុវត្តបទបញ្ញត្តិទាំងឡាយ ដែលទាក់ទងនឹងជំងឺអេដស៍ ជាពិសេសក្នុងវិស័យសិទ្ធិមនុស្ស ។

## ជំពូក ៣
## អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

មាត្រា ៥ ._ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មាន ៖

_ប្រធានមួយរូប

_អនុប្រធានប្រចាំការមួយរូប

_គណៈកម្មការប្រឹក្សាជាតិប្រយុទ្ធនឹងជំងឺអេដស៍

_អគ្គលេខាធិការមួយរូប

### ប្រធាន

មាត្រា ៦ ._នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជាប្រធាន នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយស្វ័យប្រវត្តិ ។ ក្នុងករណីដែលនាយករដ្ឋមន្ត្រី មិនអាចបំពេញមុខនាទីនេះ ដោយផ្ទាល់បាន នាយករដ្ឋមន្ត្រី អាចស្នើថ្វាយព្រះមហាក្សត្រ ដើម្បីតែងតាំងតំណាងម្នាក់ ជាប្រធាននៃអាជ្ញាធរនេះ ។

ប្រធានដឹកនាំការប្រជុំនៃគណៈកម្មការប្រឹក្សាជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

### អនុប្រធានប្រចាំការ

មាត្រា ៧ ._អនុប្រធានប្រចាំការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានឋានៈស្មើនឹងរដ្ឋមន្ត្រី ត្រូវ បានតែងតាំង ដោយព្រះរាជក្រឹត្យ ។

មាត្រា ៨ ._អនុប្រធានប្រចាំការ មានភារកិច្ច :

_ដឹកនាំ និងចាត់ចែងការងារទូទៅ នៃ អបជអ

_ចូលរួមជាស្វ័យប្រវត្តិ ក្នុងការប្រជុំពិភាក្សា នៃគណៈកម្មការប្រឹក្សាជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។ ក្នុងករណីអវត្តមានប្រធាន អនុប្រធានប្រចាំការត្រូវដឹកនាំការប្រជុំពិភាក្សានេះ ។

_កំណត់ការប្រតិបត្តិ គោលនយោបាយ ផែនការ និងយុទ្ធសាស្ត្ររួម ដែលជាសំយោគសំរេចបាន ក្រោយពីការប្រជុំពិភាក្សា នៃគណៈកម្មការប្រឹក្សាជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

_ទទួលបន្ទុកការងារទំនាក់ទំនង និងជំរុញ ឬសំរបសំរួលការធ្វើសហប្រតិបត្តិការ ជាមួយស្ថាប័នជាតិ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ក្នុងវិស័យអេដស៍ ។

_ដឹកនាំកម្មវិធីការងារ អបជអ ហើយនិងអនុញ្ញាតការចំណាយ ដែលមានចែងក្នុងក្របខ័ណ្ឌ ថវិកា អបជអ ។

_ដឹកនាំ តែងតាំង និងតំឡើងឋានន្តរសក្តិដល់បុគ្គលិកនៃ អបជអ ហើយនិងដាក់វិន័យ ទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ អបជអ សំដៅលើកកំពស់ប្រសិទ្ធិភាព សមត្ថភាព និងការស្មោគស្ម័ ក្នុងការធ្វើការងារអោយបានកំរិតខ្ពស់ជាទីបំផុត ។

មាត្រា ៩ ._ ដើម្បីបំពេញបាននូវបេសកកម្មរបស់ខ្លួន អបជអ មានសិទ្ធិអំណាចចេញបទដ្ឋានផ្សេងៗ ក្នុងវិស័យប្រយុទ្ធនឹងជំងឺអេដ្ស៍ ដែលមានលក្ខណៈជាទូទៅក្តី ជាបុគ្គលក្តី ដែលអាជ្ញាធរគ្រប់ ជាន់ថ្នាក់ត្រូវយកមកអនុវត្តជាកំហិត ។

មាត្រា ១០ ._ក្នុងការបំពេញភារកិច្ចទាំងឡាយនេះ អនុប្រធានប្រចាំការ ត្រូវមានអនុប្រធានជាជំនួយការមួយរូប ដែលមានឋានៈស្មើរដ្ឋលេខាធិការ និងទីប្រឹក្សាមួយចំនួន ។

## គណៈកម្មការប្រឹក្សាជាតិប្រយុទ្ធនឹងជម្ងឺអេដស៍

មាត្រា ១១ ._គណៈកម្មការប្រឹក្សាជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ មានសមាជិកជា រដ្ឋលេខាធិការទទួលបន្ទុកវិស័យអេដស៍មកពីក្រសួងពាក់ព័ន្ធ ៖ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងការពារជាតិ ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ក្រសួងពត៌មាន ក្រសួងទេសចរណ៍ ក្រសួងធម្មការនិងសាសនា ក្រសួងអភិវឌ្ឍន៍ជនបទ ។

សមាជិកនៃគណៈកម្មការប្រឹក្សាជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ត្រូវបានតែងតាំងឡើងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រធានស្ថាប័នពាក់ព័ន្ធ ។

ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុ អាចចូលរួមក្នុងគណៈកម្មការប្រឹក្សាជាតិ ជាអ្នកសង្កេតការណ៍ ដែលមិនត្រូវមានចំនួនលើសពីបួននាក់ឡើយ ។

មាត្រា ១២ ._គណៈកម្មការប្រឹក្សាជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ត្រូវប្រជុំយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ក្រោមអធិបតីភាពនៃប្រធាន អបជអ ឬអនុប្រធានប្រចាំការ ក្នុងករណីដែលប្រធានអវត្តមាន ។

មាត្រា ១៣ ._សមាជិកម្នាក់ៗ នៃគណៈកម្មការប្រឹក្សាជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ មានបន្ទុកអនុវត្តសេចក្តីសំរេចរបស់ អបជអ នៅក្នុងក្រសួងរបស់ខ្លួន ហើយត្រូវទទួលខុសត្រូវចំពោះមុខ អបជអ ក្នុងការអនុវត្តន៍សេចក្តីសំរេចនេះ ។

## អគ្គលេខាធិការ

មាត្រា ១៤ ._អគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ មានឋានៈស្មើអគ្គនាយក ជំនួយដោយ អគ្គលេខា ធិការរងមួយរូប ។

មាត្រា ១៥ ._អគ្គលេខាធិការដ្ឋាន មានភារកិច្ច ៖

_អនុវត្តរាល់កម្មវិធីការងាររបស់ អបជអ

_ជំរុញ និងសំរបសំរួលជាអចិន្ត្រៃយ៍ នូវវិធានការរបស់ក្រសួងពាក់ព័ន្ធ ដែលមានសមត្ថកិច្ច ក្នុងវិស័យដែលបានចែងខាងលើ ។

_ធ្វើការបូកសរុបរាល់សកម្មភាពការងាររបស់ អបជអ ជូនប្រធាន និងគណៈរដ្ឋមន្ត្រី អំពីស្ថានភាពអេពីដេមីសាស្ត្រ រាប់បញ្ចូលទាំង ៖

_លទ្ធផល នៃការអង្កេតឃ្លាំមើលមេរោគអេដស៍ ការអង្កេតស្រាវជ្រាវ ការប្រព្រឹត្ត ឬការសិក្សាស្រាវជ្រាវផ្សេងៗទៀត រួមទាំងការបកប្រែនូវទិន្នន័យនានាផង ។

_ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច-សង្គម ដែលបណ្តាលមកពីការរាតត្បាតនៃជម្ងឺទៅលើបណ្តាស្ថាប័ននានានៅក្នុងសង្គម រួមមានការងារទេសចរណ៍ ពាណិជ្ជកម្ម ការពារជាតិ ។ល។

_ការបង្កើតឡើងថ្មី នូវការព្យាបាល ការបង្ការ ការធ្វើរោគវិនិច្ឆ័យថ្មីៗ ដែលមានឥទ្ធិពលលើទូទាំងប្រទេស ។

_គ្រប់គ្រងបណ្តាកម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺអេដស៍

_រៀបចំផែនការអភិវឌ្ឍន៍តាមបច្ចេកទេសក្នុងវិស័យអេដស៍

_ពិនិត្យមើលលើបេសកកម្មរបស់ជំនាញការ-ទីប្រឹក្សាបរទេស

_គ្រប់គ្រង និងដឹកនាំនាយកដ្ឋានចំណុះ

_សំរបសំរួលការងារពាក់ព័ន្ធនឹងថវិកា ហិរញ្ញវត្ថុ គណនេយ្យ រដ្ឋបាល និងបុគ្គលិក

## ជំពូក ៤

## អគ្គភាពរដ្ឋបាល និងបច្ចេកទេស

មាត្រា ១៦ ._អគ្គលេខាធិការដ្ឋាន មាននាយកដ្ឋានចំណុះពីរ ៖ នាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ និងនាយកដ្ឋានបច្ចេកទេស ដែលចាំបាច់ ក្នុងការបំពេញភារកិច្ច ដើម្បីអោយបានសំរេចនូវគោលបំណងរបស់ខ្លួន ។

អគ្គលេខាធិការដ្ឋាន ត្រូវមានបុគ្គលិក រដ្ឋបាល និងបច្ចេកទេស ដែលមានការអប់រំហ្វឹកហ្វឺនយ៉ាងត្រឹមត្រូវ និងមានគុណសម្បត្តិខ្ពស់ ដើម្បីចាត់ចែងអង្គភាពនេះ ។

មាត្រា ១៧ ._ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ អបជអ ត្រូវបានកំណត់ដោយប្រកាសរបស់ អបជអ ។

## ជំពូក ៥

## ប្រភពធនធាន និងការចាត់ចែង

មាត្រា ១៨ ._អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ជាស្ថាប័នជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានទិសដៅមិនស្វែងរកចំណេញឡើយ ។

អបជអ ត្រូវមានថវិកាស្វយ័តមួយរបស់ខ្លួន សំរាប់ការរៀបចំនិងការប្រព្រឹត្តទៅ ព្រមទាំងសំរាប់កិច្ចប្រតិបត្តិការទាំងឡាយរបស់ខ្លួន ។

ធនធាន និងថវិកានេះត្រូវបានផ្គត់ផ្គង់ដោយ ៖

_វិភាគទានរបស់ថវិកាជាតិ ។

_ទ្រព្យ និងរបស់មានតម្លៃ អំណោយ និងប្រាក់ជំនួយដែលផ្តល់ជូន អបជអ ពីស្ថាប័នរដ្ឋាភិបាល ពីរដ្ឋាភិបាលបរទេស ពីអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ពីស្ថាប័នផ្សេងៗ ពីក្រុមហ៊ុន និងពីបុគ្គល ។

មាត្រា ១៩ ._អបជអ អាចសុំ អាចទទួល អាចទិញ ឬពុំនោះទេ អាចសុំពីស្ថាប័នរដ្ឋាភិបាល ឬអន្តររដ្ឋាភិបាល ឬ ពីបុគ្គល ឬពីក្រុមហ៊ុន ឬពីស្ថាប័នឯទៀតៗ ដោយអំណោយក្តី ឬដោយមធ្យោបាយឯណាទៀតក្តី នូវ ធនធានទាំងឡាយ រាប់ទាំងប្រាក់កាស និងអំណោយដែលមានប្រយោជន៍ ឬដែលត្រូវការចាំបាច់ក្នុងការធ្វើអោយបានសំរេចគោលដៅរបស់ខ្លួន ។ អបជអ អាចរក្សាទុក អាចជាម្ចាស់ អាចគ្រប់គ្រង អាចប្រើប្រាស់ នូវធនធានទាំងឡាយខាងលើនេះ ។ អបជអ អាចទិញចលនៈ ឬអចលនវត្ថុណាដែលឃើញថាចាំបាច់សំរាប់សកម្មភាពរបស់ខ្លួន ។

មាត្រា ២០ ._អបជអ អាចអោយបុគ្គលឯកជន ឬក្រុមហ៊ុន ឬឯកជនផ្សេងៗទៀតបង់ប្រាក់លើផលិតផល ឬ សេវាកម្ម ដែលខ្លួនផ្តល់អោយ ។ តម្លៃទាំងនេះមិនត្រូវអោយលើសពីថ្លៃដើមឡើយ ។

មាត្រា ២១ ._អបជអ ត្រូវមានបែបបទហិរញ្ញវត្ថុរបស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុអោយទៀតទាត់ ។ គណនេយ្យចំណាយចំណូលរបស់ អបជអ ត្រូវបើកចំហរអោយមានការត្រួតពិនិត្យ ពីសំណាក់អង្គការឯករាជ្យណាមួយ ឬពីសំណាក់ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុ ឬប្រទេសផ្តល់ជំនួយឧបត្ថម្ភ ។

មាត្រា ២២ ._អបជអ ត្រូវបានជាម្ចាស់សម្បត្តិទាំងឡាយ ដែលខ្លួនរកបាន ។

## ជំពូក ៦

## អវសានប្បញ្ញត្តិ

មាត្រា ២៣ ._បទបញ្ញត្តិទាំងឡាយណាផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៤._រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ទេសរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការពាក់ព័ន្ធផ្សេងៗទៀត ត្រូវអនុវត្តអោយបានសំរេចនូវអនុក្រឹត្យនេះ ទៅតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ២៥ ._អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមករា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហ៊ុន សែន